-បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០០ ស្តីពីការអភិវឌ្ឍន៍តំបន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សំរេច**

**មាត្រា ១ .-** មាត្រា២ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០០០ ត្រូវបានកែតំរូវដូចខាងក្រោម :

មាត្រាថ្មី២ : ចាត់ទុកជាមោឃៈ នូវប័ណ្ណសំគាល់សិទ្ធិលេខ $A_3$ 0508, $A_3$ 0048, $A_3$ 0455, $A_3$ 0067, $A_3$ 0509, $A_3$ 0615, $A_3$ 0512, $A_{III}$ 0260, $A_{III}$ 0330, $A_{III}$ 0210, $A_{III}$ 0211, $A_{III}$ 0240, $A_{III}$ 0002, $A_{III}$ 0003, $A_I$ 0037, $A_I$ 0176, $A_I$ 0003, $A_I$ 0789, $A_3$ 0682, $A_3$ 0674, $A_3$ 0031 និងឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងការផ្តល់សិទ្ធិកាន់កាប់ដីធ្លី ស្ថិតនៅក្នុងតំបន់ដូចមានចែងនៅក្នុងមាត្រា១ ដោយប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អភិបាលក្រុងព្រះសីហនុ កំពង់ផែស្វយ័តក្រុងព្រះសីហនុ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីស្ថិតនៅក្នុងបរិវេណដូចបានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យ លេខ ៥៥ អនក្រ.បក

## ស្តីពី ការផ្ទេរតំណែងនាយឧទ្ទេសិកា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ .-ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៥.០០០ លានរៀល (ប្រាំពាន់លានរៀល) ពីជំពូក ៥០ (ចំណាយផ្សេងៗ ឥណទានឧបសម្ព័ន្ធថវិកា ឬ សង្កាត់) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់ តូច) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ។

មាត្រា ២ .- ឥណទានថវិកា ក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ៣០៣ អនក្រ.បក**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា